អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សូមគោរពជូន
សម្តេចតិបុលសេនាតន្តី សាយ ឈុំ
ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

សម្តេចប្រធាន,

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លាដែលសម្តេចប្រធាន ត្រូវបានព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ប្រោសព្រះរាជទានគោរមងារជា **សម្តេចតិបុលសេនាតន្តី សាយ ឈុំ** ខ្ញុំក្នុងនាមថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានសេចក្តីរំភើបរីករាយឥតឧបមា សូមសម្តែងនូវអំណរសាទរយ៉ាងកក់ក្តៅជូនសម្តេច ។

គោរមងារជា **សម្តេចតិបុលសេនាតន្តី** ជាសក្ខីភាពបង្ហាញឱ្យឃើញនូវសមត្ថភាពការងារ និង កិច្ចខិតខំប្រឹងប្រែងដែលសម្តេចប្រធានបានរួមចំណែកក្នុងការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍក្នុងតួនាទីជាប្រមុខដឹកនាំកំពូលស្ថាប័ននីតិបញ្ញត្តិមួយរូបនៃព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំសូមជូនពរ **សម្តេចតិបុលសេនាតន្តី** មានសុខភាពល្អ និង ទទួលបាននូវជោគជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមដើម្បីបម្រើជាតិមាតុភូមិរបស់សម្តេចប្រធាន។

សូមសម្តេចប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥

ឧបនាយករដ្ឋមន្ត្រី
និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង ម៉ូលី

អាសយដ្ឋាន: អគារលេខ ១៦ ផ្លូវលេខ ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារ (៨៥៥-២៣) ៨៨៥ ១២៩